# សុន្ទរកថា
## អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន
## ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
## ថ្លែងក្នុង
## ពិធីប្រកាសដាក់ឲ្យប្រើប្រាស់ជាផ្លូវការ នូវ «ចក្ខុវិស័យ និង យុទ្ធសាស្ត្រ ស្ដីពីសុខដុមនីយកម្ម កិច្ចការកែទម្រង់គន្លឹះ នៃរាជរដ្ឋាភិបាល»

រាជធានីភ្នំពេញ, ថ្ងៃ អង្គារ ១៣ កើត, ខែអាសាឍ, ឆ្នាំម្សាញ់, សប្តស័ក, ព.ស. ២៥៦៩
ត្រូវនឹងថ្ងៃទី ៨ ខែ កក្កដា គ.ស. ២០២៥, សូហ្វីតែលភ្នំពេញ, វេលាម៉ោង ៩ ព្រឹក

*****+*****

- ឯកឧត្តម, លោកជំទាវ, សមាជិក-សមាជិកា នៃរាជរដ្ឋាភិបាល;
- ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, ថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន, ភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិ, សមាជិក-សមាជិកា នៃអង្គពិធី, ជាទីមេត្រី!

ថ្ងៃនេះ, ខ្ញុំមានកិត្តិយសដ៏ឧត្តុង្គឧត្តម និង សេចក្តីសោមនស្សក្រៃលែង ដោយបានទទួលបុព្វសិទ្ធិដ៏ខ្ពង់ខ្ពស់បំផុត ពី **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ធ្វើជាអធិបតី ក្នុង ពិធីប្រកាសដាក់ឲ្យប្រើប្រាស់ជាផ្លូវការ នូវ «ចក្ខុវិស័យ និង យុទ្ធសាស្ត្រ ស្ដីពីសុខដុមនីយកម្ម កិច្ចការកែទម្រង់គន្លឹះ នៃរាជរដ្ឋាភិបាល» ។ ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះ ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, សមាជិក-សមាជិកានៃអង្គពិធី ដែលបានឆ្លៀតពេលដ៏មានតម្លៃ អញ្ជើញចូលរួមក្នុងពិធីដ៏មានអត្ថន័យ នាព្រឹកនេះ ។

ផ្អែកលើរបាយការណ៍ របស់ឯកឧត្តម **រស់ សីលវ៉ា**, រដ្ឋលេខាធិការ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, ពិធីនេះ ត្រូវបានរៀបចំឡើង ក្រោមការសម្របសម្រួល និង កិច្ចសហការជិតស្និទ្ធ រវាងអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ, អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌, និង អគ្គលេខាធិការដ្ឋាន នៃគណៈ-កម្មាធិការដឹកនាំការកែទម្រង់ច្បាប់, ក្នុងក្របខណ្ឌនៃយន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះ នៃរាជរដ្ឋាភិបាល, ហៅកាត់ថា យ.ស.ក. ។

ការខិតខំរៀបចំបាន នូវឯកសារ «**ចក្ខុវិស័យ និង យុទ្ធសាស្ត្រ ស្តីពីសុខដុមនីយកម្ម កិច្ចការកែទម្រង់គន្លឹះ នៃរាជរដ្ឋាភិបាល**», រហូតត្រូវបានប្រកាស ដាក់ឲ្យប្រើប្រាស់ជាផ្លូវការ នាថ្ងៃនេះ, សបញ្ជាក់ឲ្យឃើញច្បាស់ អំពីប្រសិទ្ធភាព និង ស័ក្តិសិទ្ធភាព នៃការសម្របសម្រួល និង កិច្ចសហការអន្តរការដ្ឋាន នៃកម្មវិធីកែទម្រង់គន្លឹះ របស់រាជរដ្ឋាភិបាល ដែលមានភាពប្រទាក់ក្រឡាគ្នា, ពោលគឺ **កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, កម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, កម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ, កម្មវិធីកែទម្រង់ប្រព័ន្ធយុត្តិធម៌, និង កម្មវិធីកែទម្រង់ច្បាប់** ។

កិច្ចការកែទម្រង់គន្លឹះ ទាំង ៥ នេះ ក្រសោបចូល នូវសមាសភាគ ដ៏សំខាន់ ចំនួន ៥ នៃការកែទម្រង់អភិបាលកិច្ច របស់កម្ពុជា រួមមាន៖ (១). ការគ្រប់គ្រងធនធានហិរញ្ញវត្ថុ ប្រកបដោយប្រសិទ្ធភាព និង ស័ក្តិសិទ្ធភាព; (២). ការកំណត់បែងចែកមុខងារច្បាស់លាស់, ការ-ធ្វើប្រតិភូកម្មអំណាចត្រឹមត្រូវ និង ការសម្របសម្រួលអនុវត្តមុខងារ ប្រកបដោយប្រសិទ្ធ-ភាព; (៣). ការកសាងធនធានមនុស្ស និង ស្ថាប័នសាធារណៈ ប្រកបដោយគុណភាព, ភាពស្អាតស្អំ, ភាពឆ្លាតវៃ និង សមត្ថភាព; (៤). ការអភិវឌ្ឍប្រព័ន្ធច្បាប់ និង យុត្តិធម៌ គ្រប់ជ្រុងជ្រោយ និង ប្រកបដោយសង្គតិភាព និង ប្រសិទ្ធភាព; និង (៥). ការលើកកម្ពស់ការ-គោរពច្បាប់ ព្រមទាំង ភាពត្រឹមត្រូវ និង ប្រសិទ្ធភាព ក្នុងការអនុវត្តច្បាប់ ពីសំណាក់មន្ត្រីអនុវត្តច្បាប់ និង មន្ត្រីតុលាការ ។

ជាការពិត, ការកែទម្រង់ស៊ីជម្រៅ និង មុតស្រួច គឺជារបៀបវារៈអាទិភាព របស់រាជរដ្ឋា-ភិបាល, ទាំងក្នុងនីតិកាល បន្តបន្ទាប់កន្លងទៅ និង ក្នុងនីតិកាលទី ៧ នេះ នៃរដ្ឋសភា ។ សមិទ្ធផល

នៃកិច្ចការកែទម្រង់ ក្នុងគ្រប់វិស័យខាងលើ, ដែលសម្រេចបានមក ពីការជំរុញអនុវត្តយ៉ាងសកម្ម ក្នុងឆន្ទៈមោះមុតឥតរាថយ នូវ **យុទ្ធសាស្ត្រចតុកោណ** ទាំង ៤ ដំណាក់កាល ជាបន្តបន្ទាប់ កន្លងទៅ, បានរួមចំណែកយ៉ាងសំខាន់ ដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិ ទៅតាមមុខសញ្ញារបស់ខ្លួន, ក្នុងនោះ រួមមាន៖ ការធានាបាននូវស្ថិរភាព និង ចីរភាពនៃកំណើនសេដ្ឋកិច្ច, ការពង្រឹងអភិបាលកិច្ច, ការពង្រឹងជំនឿទុកចិត្ត ពីសាធារណជន មកលើវិស័យយុត្តិធម៌, ការលើកកម្ពស់ប្រសិទ្ធភាពនៃច្បាប់, ការលើកកម្ពស់គុណភាពនៃការផ្តល់សេវាសាធារណៈ ។ល។ សម្រាប់នីតិកាលទី ៧ នៃរដ្ឋសភា, ក្រោមការដឹកនាំដ៏ត្រឹមត្រូវ, ស្វាហាប់, ប៉ិនប្រសប់ និង ឈ្លាសវៃ របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**, **នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**, រាជរដ្ឋាភិបាល បានដាក់ឲ្យអនុវត្ត នូវ **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** ដើម្បី កំណើន, ការងារ, សមធម៌, ប្រសិទ្ធភាព, និង ចីរភាព, ជាមួយនឹង **អាទិភាពគន្លឹះ** ចំនួន ៥ គឺ៖ «មនុស្ស, ផ្លូវ, ទឹក, ភ្លើង, និង បច្ចេកវិទ្យា, ជាពិសេស គឺ **បច្ចេកវិទ្យាឌីជីថល**», និង ដោយបន្តកំណត់យក **ការកែទម្រង់ និង ការពង្រឹងអភិបាលកិច្ច** ជា **ស្នូលនៃយុទ្ធសាស្ត្រ** ដែលផ្តោតអាទិភាព លើការធ្វើទំនើបកម្មស្ថាប័នរដ្ឋ ឲ្យក្លាយជារដ្ឋបាលសាធារណៈទំនើប ប្រកបដោយសមត្ថភាពខ្ពស់, ខ្លាំង, វៃឆ្លាត និង ស្អាតស្អំ, តាមរយៈការអនុវត្តសិទ្ធិអំណាចរដ្ឋ ខាងផ្នែកនយោបាយ, សេដ្ឋកិច្ច និង រដ្ឋបាល ក្នុងការដឹកនាំ, ការគ្រប់គ្រង និង ការចាត់ចែងកិច្ចការប្រទេស, ជាពិសេស ការធានានិរន្តរភាពនៃតួនាទី និង កិច្ចដំណើរការនៃរដ្ឋបាលសាធារណៈ ដោយយកចិត្តទុកដាក់ខ្ពស់ លើផលប្រយោជន៍ជាតិ និង ប្រជាជន, ព្រមជាមួយនឹងការកសាងជាតិ និង ការពង្រឹងនីតិរដ្ឋ សំដៅគាំទ្រដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ប្រកបដោយបរិយាបន្ន និង ចីរភាព ។

## *ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី !*

ក្នុងបរិការណ៍នៃការប្រែប្រួលយ៉ាងរហ័ស និង ពិបាកប៉ាន់ស្មានបាន នូវសភាពការណ៍សង្គម-សេដ្ឋកិច្ច, ទាំងក្នុងកម្រិតតំបន់ និង សកល ដូចបច្ចុប្បន្ន, យើងគ្មានជម្រើសអ្វីដែលល្អជាងការបន្តយកចិត្តទុកដាក់ ពង្រឹង និង សម្រួច កិច្ចការកែទម្រង់របស់យើងនោះទេ ។ ក្នុងន័យនេះ, ទស្សនវិជ្ជា៖ «កែទម្រង់-រស់, មិនកែ-ទម្រង់-ស្លាប់» របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**, អតីតនាយករដ្ឋមន្ត្រី និង បច្ចុប្បន្ន ជាប្រធានព្រឹទ្ធសភា, ក្នុងស្មារតី «ធ្វើបណ្តើរ, រៀនបណ្តើរ, និង កែលម្អបណ្តើរ», នៅតែត្រឹមត្រូវ ដែលត្រូវបន្តជំរុញអនុវត្តជាប្រចាំ ។ ទស្សនវិជ្ជានេះ មិនត្រឹមតែក្លាយជាប្រភពដ៏សំខាន់, មិនចេះរីងស្ងួត, នៃស្មារតីកែទម្រង់មិនចេះនឿយហត់ ប៉ុណ្ណោះទេ; ប៉ុន្តែថែមទាំង ក្លាយជាកម្លាំងចលករនៃ

ការបន្តការកែទម្រង់ ឲ្យកាន់តែប្រសើរ និង កាន់តែមានប្រសិទ្ធភាព ដើម្បីឆ្លើយតបបាន កាន់តែល្អ ទៅនឹងសភាពការណ៍ដែលកាន់តែស្មុគស្មាញ ព្រមទាំង ដើម្បីឆ្លើយតបទៅនឹង បំណងប្រាថ្នា និង តម្រូវការកាន់តែខ្ពស់ របស់ប្រជាជន ។

ច្បាស់ណាស់ថា សមិទ្ធផលជាប្រវត្តិសាស្ត្រនៃការកែទម្រង់ និង ការអភិវឌ្ឍ, ដែលយើង ទាំងអស់គ្នាកំពុងតែក្រេបជញ្ជក់ ជាមនុញ្ញផលនេះ, អាចសម្រេចបានមក ដោយសារកិច្ចប្រឹងប្រែង រួមគ្នាជាធ្លុងមួយ ជាមួយនឹងឆន្ទៈមុតស្រួចឥតរាថយ នៃថ្នាក់ដឹកនាំ និង មន្ត្រីរាជការពាក់ព័ន្ធ គ្រប់លំដាប់ថ្នាក់ នៃគ្រប់ក្រសួង-ស្ថាប័នជាតិ និង រដ្ឋបាលថ្នាក់ក្រោមជាតិ នៅក្រោមម្លប់ ដ៏ត្រជាក់នៃ «**សន្តិភាព**» ដែល **អគ្គមហារដ្ឋបុរសដ៏ឆ្នើមគ្មានពីរ** នៃយើង គឺ សម្តេច-អគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** បាននាំមកជូនជាតិ និង ប្រជាជនកម្ពុជា តាមរយៈ ការតស៊ូលះបង់ដ៏ធំធេងបំផុត, ពោលគឺ ដោយប្រថុយជីវិតផ្ទាល់ខ្លួន ដើម្បីបុព្វហេតុដ៏ឧត្តុង្គ-ឧត្តម មិនអាចកាត់ថ្លៃបាន ។ សមិទ្ធផល និង បទពិសោធ ក្នុងរយៈពេលជាង ២០ ឆ្នាំកន្លងទៅ បានផ្តល់មេរៀន ដ៏មានតម្លៃ ជាច្រើនអនេក និង បានធ្វើឲ្យយើង រឹតតែជឿជាក់ លើភាពត្រឹមត្រូវ នៃទស្សនវិស័យ របស់យើង នោះគឺ៖ យើងត្រូវកែទម្រង់តាមសេចក្តីត្រូវការរបស់កម្ពុជា, ក្នុង បរិបទសង្គម-សេដ្ឋកិច្ច, ស្ថាប័ន, និង រដ្ឋបាល របស់កម្ពុជា, ក្នុងភាពជាម្ចាស់របស់កម្ពុជា, និង ជាពិសេស ក្នុងការទទួលខុសត្រូវ របស់កម្ពុជា ចំពោះជោគវាសនាអនាគតជាតិយើង ដោយ ខ្លួនឯង ។ យើងទទួលស្គាល់ថា ការកែទម្រង់ ជាការងារដ៏លំបាកស្មុគស្មាញ, ដោយម្ខាង, យើង ត្រូវជួបប្រទះបញ្ហាប្រឈមច្រើន, ទាំងផ្នែកផ្នត់គំនិត, ឆន្ទៈ, ភាពជាអ្នកដឹកនាំ, ការប៉ះពាល់ ផលប្រយោជន៍, សមត្ថភាព, ធនធានមនុស្ស និង បញ្ហាបច្ចេកទេស; ក៏ប៉ុន្តែ ម្ខាងទៀត, យើង ត្រូវតែចាប់ផ្តើមធ្វើ ដោយមិនបង្អង់រង់ចាំទាល់តែមានសមត្ថភាព, ធនធាន និង មធ្យោបាយ គ្រប់គ្រាន់នោះឡើយ, ក្នុងស្មារតី **«ធ្វើបណ្តើរ, រៀនបណ្តើរ, និង កែលម្អបណ្តើរ»,** ដូចខ្ញុំ បានគូសបញ្ជាក់ខាងលើ ។ ដូច្នេះ, ការកែទម្រង់ អាចប្រៀបប្រដូចបានទៅនឹងការដាំ និង ការ- ថែរក្សាដើមឈើយ៉ាងដូច្នោះដែរ ដែលតម្រូវឲ្យមានភាពអត់ធ្មត់ និង ទ្រាំជម្នះភាពនឿយ ហត់, ហើយជួនកាល រួមទាំងភាពជូរចត់ផងដែរ; ក៏ប៉ុន្តែ, ផ្លែផ្កាដែលទទួលបានពីកិច្ច ខិតខំ ដ៏មោះមុត និង ការព្យាយាមឥតរាថយនោះ គឺ៖ ភាពរីករាយ, ក្តីសុខក្សេមក្សាន្ត និង ការរីក-ចម្រើនឈានឡើង ជាបន្តបន្ទាប់ របស់សង្គមជាតិ ប្រកបដោយវិបុលភាព និង ចីរភាព ។

***ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី !***

មុននេះបន្តិច, ខ្ញុំបានគូសរំលេច នូវសមាសភាគសំខាន់ ចំនួន ៥ នៃប្រព័ន្ធអភិបាលកិច្ច ដែលជាកម្មវត្ថុនៃការយកចិត្តទុកដាក់ នៅក្រោមកម្មវិធីកែទម្រង់គន្លឹះ ទាំង ៥ របស់រាជរដ្ឋាភិបាល ។ តទៅនេះ, ខ្ញុំសូមអធិប្បាយបន្ថែម ដោយសង្ខេបបំផុត អំពីទំនាក់ទំនង និង ភាពប្រទាក់ក្រឡាគ្នា, ដោយផ្ទាល់ និង ដោយប្រយោល, រវាងសមាសភាគ ទាំង ៥ នៃកិច្ចការកែទម្រង់អភិបាលកិច្ច របស់រាជរដ្ឋាភិបាល ដូចខាងក្រោម៖

ទី១). **មុខងារ៖** បច្ចុប្បន្ន, ការវិភាគមុខងារ និង រចនាសម្ព័ន្ធ របស់ក្រសួង-ស្ថាប័ន គឺជាកិច្ចការកែទម្រង់គន្លឹះ ដែលស្ថិតក្នុងក្របខណ្ឌនៃការអនុវត្តវិធានការគន្លឹះ ក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ នៃរាជរដ្ឋាភិបាល សម្រាប់នីតិកាលទី ៧ នៃរដ្ឋសភា ។ ចំពោះរដ្ឋបាលថ្នាក់ក្រោមជាតិ, ការផ្ទេរមុខងារទាមទារឲ្យមានការគិតគូរដាក់បញ្ចូល ជាមួយនឹងការផ្ទេរធនធានហិរញ្ញវត្ថុ និង ធនធានមនុស្ស ដើម្បីគាំទ្រដល់ការអនុវត្តមុខងារដែលត្រូវបានផ្ទេរ ប្រកបដោយប្រសិទ្ធភាព និង ស័ក្តិសិទ្ធភាព ។

ទី២). **ហិរញ្ញវត្ថុ៖** ក្នុងបរិបទដែលសមិទ្ធកម្ម ក្លាយជាគោលដៅនៃការគ្រប់គ្រង ក្នុងរដ្ឋបាលសាធារណៈកម្ពុជា, ទាំងថ្នាក់ជាតិ និង ថ្នាក់ក្រោមជាតិ, ថវិកា គឺជាឧបករណ៍ស្នូលមួយ នៃគោលនយោបាយ ឬ អាចនិយាយម្យ៉ាងទៀតថា ថវិកា ត្រូវផ្សារភ្ជាប់ទៅនឹងគោលនយោបាយ ។ ជារួម, ថវិកា ត្រូវបានប្រើប្រាស់ ដើម្បីសម្រេចសមិទ្ធផលដែលត្រូវបានគ្រោងទុក ។ នេះគឺជាគោលនយោបាយនៃ **ថវិកាសមិទ្ធកម្ម** ក្នុងក្របខណ្ឌនៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ។ ដោយឡែក, ក្នុងក្របខណ្ឌនៃកិច្ចការកែទម្រង់គន្លឹះ នៃរាជរដ្ឋាភិបាល, ហិរញ្ញវត្ថុ ឬ ថវិកា ត្រូវគាំទ្រ និង មានសង្គតិភាព ទៅនឹងគោលនយោបាយកែទម្រង់វិមជ្ឈការ និង វិសហមជ្ឈការ, គោលនយោបាយកែទម្រង់មុខងារសាធារណៈ, គោលនយោបាយកែទម្រង់ប្រព័ន្ធយុត្តិធម៌, និង គោលនយោបាយកែទម្រង់ច្បាប់ ។

ទី៣). **ធនធានមនុស្ស៖** ការអភិវឌ្ឍធនធានមនុស្ស ក្នុងមុខងារសាធារណៈ គឺជាកិច្ចការចម្បង ក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ, ដែលជាអាទិភាពខ្ពស់បំផុតមួយ ក្នុង **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១** ។ សម្រាប់នីតិកាលទី ៧ នៃរដ្ឋសភា, រាជរដ្ឋាភិបាល បានដាក់ចេញសម្រាប់អនុវត្ត នូវអាទិភាពគន្លឹះ ចំនួន ៣ ក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ រួមមាន៖ ក). ពង្រឹងប្រព័ន្ធជ្រើសរើសមន្ត្រីចូលបម្រើការងារ, ខ). ពង្រឹងសមត្ថភាពមន្ត្រី និង សមិទ្ធកម្មស្ថាប័ន ដើម្បីលើកកម្ពស់គុណភាពការងារ, និង គ).

ដាក់ឲ្យអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម ។ អាទិភាពគន្លឹះ ទាំង ៣ នេះ ផ្តោតលើការពង្រឹងធនធានមនុស្ស ក្នុងមុខងារសាធារណៈ, ពោលគឺ មន្ត្រីរាជការនៅគ្រប់ជាន់ថ្នាក់ ។

**ទី៤). ប្រព័ន្ធយុត្តិធម៌៖** ការកែទម្រង់ប្រព័ន្ធយុត្តិធម៌ អាចមានលក្ខណៈពិសេស ពីទិដ្ឋភាព ទាំង ៣ ខាងលើ នៅត្រង់ថា ការងារនេះ ផ្តោតលើវិស័យយុត្តិធម៌ ឬ និយាយម្យ៉ាងទៀតថា ការកែទម្រង់នេះ គឺជាសកម្មភាពការងារ នៅក្នុងអំណាចមួយដោយឡែក ផ្សេងពីអំណាចនីតិប្រតិបត្តិ ឬ រាជរដ្ឋាភិបាល, ពោលគឺ អំណាចតុលាការ ។ យ៉ាងណាមិញ, ពាក់ព័ន្ធនឹងមុខងារ, ហិរញ្ញវត្ថុ ឬ ថវិកា, និង ធនធានមនុស្ស ឬ មន្ត្រីរាជការ, ការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌ នៅតែមានទំនាក់ទំនង, ដោយផ្ទាល់ និង ដោយប្រយោល, ជាមួយនឹងការកែទម្រង់ ៤ ផ្សេងទៀត ដោយខានមិនបាន ។ ការកែទម្រង់ប្រព័ន្ធយុត្តិធម៌, ដែលមានគោលដៅជាយុទ្ធសាស្ត្រ ផ្តោតលើការពង្រឹងគោលការណ៍នីតិរដ្ឋ, ការពង្រឹងការប្រយុទ្ធប្រឆាំងអំពើបំពាន ដោយអយុត្តិធម៌ក្នុងសង្គម, និង ការពង្រឹងជំនឿទុកចិត្តពីសាធារណជន មកលើវិស័យយុត្តិធម៌, គឺជាកត្តារួមចំណែកដ៏សំខាន់, មិនត្រឹមតែក្នុងការពង្រឹងអភិបាលកិច្ច និង លើកកម្ពស់ប្រសិទ្ធភាពនៃច្បាប់ និង ប្រព័ន្ធយុត្តិធម៌ ក្នុងសង្គមជាតិប៉ុណ្ណោះទេ, ប៉ុន្តែសំខាន់ជាងនេះទៀត ក៏រួមចំណែកផងដែរ ក្នុងការធានាថែរក្សាស្ថិរភាពសង្គម, សណ្តាប់ធ្នាប់សាធារណៈ និង ភាពសុខដុមរមនា ក្នុងសង្គមជាតិ ដែលជាបុព្វលក្ខខណ្ឌ សម្រាប់ជោគជ័យនៃកិច្ចការកែទម្រង់ដទៃទៀត របស់រាជរដ្ឋាភិបាល ។ និង

**ទី៥). ច្បាប់៖** ការកែទម្រង់ច្បាប់ ផ្តោតលើវដ្តនៃច្បាប់, ទាំងក្នុងដំណាក់កាលរៀបចំ, ដំណាក់កាលអនុវត្ត និង ដំណាក់កាលត្រួតពិនិត្យប្រសិទ្ធភាពនៃការអនុវត្ត, ក្នុងគោលបំណងពង្រឹង និង លើកកម្ពស់គោលការណ៍នីតិរដ្ឋ, សន្តិសុខគតិយុត្ត, ឧត្តមានុភាពគតិយុត្ត, ព្រមទាំងគុណភាព និង ប្រសិទ្ធភាពនៃច្បាប់ ។ គុណភាព, សង្គតិភាព, ប្រសិទ្ធភាព និង ស័ក្តិសិទ្ធភាព នៃការរៀបចំ និង ការអនុវត្តច្បាប់ នឹងក្លាយជាកម្លាំងចលករប្រកបដោយថាមភាព ដែលគាំទ្រដល់ទិដ្ឋភាព ចំនួន ៤ ផ្សេងទៀតខាងលើ ។

## ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី !

ច្បាស់ណាស់ថា, និយាយជារួម, គ្រប់ការងារកែទម្រង់ អាចសម្រេចជោគជ័យទៅបានតាមការរំពឹងទុក ដើម្បីបម្រើឧត្តមប្រយោជន៍នៃប្រទេស និង ប្រជាជនយើង លុះត្រាតែមានការចូលរួមយ៉ាងសកម្ម និង កិច្ចសហការល្អ ក្នុងចំណោមគ្រប់តួអង្គអនុវត្ត ដែលមានការពាក់ព័ន្ធទាំងអស់ ។ និយាយដោយឡែក, ដើម្បីសម្រេចបាននូវ សុខដុមនីយកម្ម នៃកិច្ចការ

កែទម្រង់គន្លឹះ ទាំង ៥ របស់រាជរដ្ឋាភិបាល ប្រកបដោយប្រសិទ្ធភាព និង ប្រសិទ្ធផល តាមការរំពឹងទុក, ក្រសួង-ស្ថាប័នទាំងអស់ នៅគ្រប់កម្រិត ត្រូវប្រកាន់យកនូវ **អភិក្រម «ធ្វើការប្រទាក់ក្រឡាគ្នា ជារដ្ឋាភិបាលទាំងមូល»**, ទាំងក្នុងដំណាក់កាលរៀបចំ និង ក្នុងដំណាក់កាលអនុវត្ត, ជាពិសេស ចំពោះការងារដែលមានលក្ខណៈអន្តរកែទម្រង់ និង មានភាពប្រទាក់-ក្រឡាគ្នា; និង ត្រូវមានកិច្ចសហការស្អិតល្មួត រវាងតួអង្គពាក់ព័ន្ធនានា, ដោយចៀសវាង នូវការធ្វើការងារដាច់ដោយដុំ, ស្របតាមអភិក្រម «ជវភាពនៃប្រព័ន្ធតួអង្គតែមួយ» នៃ **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី ១**, ដើម្បីដោះស្រាយបញ្ហាប្រឈមផងទាំងពួង ដែលមានលក្ខណៈអន្តរវិស័យ ប្រកបដោយប្រសិទ្ធភាព និង ស័ក្តិសិទ្ធភាព ។ ក្នុងស្មារតីនេះ, ខ្ញុំសូមយកឱកាសដ៏វិសេសនេះ ផ្តល់នូវទស្សនៈផ្ទាល់ខ្លួនមួយចំនួន ជូនអគ្គលេខាធិការដ្ឋាន និង លេខាធិការដ្ឋាន នៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់គន្លឹះ ទាំង ៥ របស់រាជរដ្ឋា-ភិបាល, ក៏ដូចជា ក្រសួង-ស្ថាប័ន និង រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការអនុវត្តកិច្ចការកែទម្រង់ក្នុងដែនសមត្ថកិច្ចរៀងខ្លួន តាមអភិក្រម ចំនួន ៤ ដូចខាងក្រោម៖

អភិក្រមទី ១). **ការរក្សាគំហើញទាំងមូល (Holistic View)** ដែលសំដៅថា កម្មវិធីកែទម្រង់មួយត្រូវពឹងផ្អែក និង អាស្រ័យ លើកម្មវិធីកែទម្រង់ផ្សេងទៀត ដោយប្រទាក់ក្រឡាគ្នា និង មានទំនាក់ទំនងទៅវិញទៅមក មិនអាចខ្វះបាន, ពោលគឺ **ជាប្រព័ន្ធនៃការកែទម្រង់** ។

អភិក្រមទី ២). **ការចូលរួមចំណែកតាមតួនាទី** ដែលសំដៅថា កម្មវិធីកែទម្រង់នីមួយៗ បំពេញឲ្យគ្នាទៅវិញទៅមក មិនអាចខ្វះបាន ទៅតាមតួនាទី, មុខងារ និង សមត្ថកិច្ច ក្នុងក្របខណ្ឌនៃមុខងារស្ថាប័នរៀងខ្លួន ដែលត្រូវបានកំណត់ដោយច្បាប់ និង បទប្បញ្ញត្តិ ជាធរមាន ។

អភិក្រមទី ៣). **ការរក្សាភាពជាម្ចាស់ និង ការគាំទ្រកិច្ចសហការស្អិតល្មួត** ដែលសំដៅដល់, ម្ខាង, ការគោរពភាពជាម្ចាស់ លើវឌ្ឍនភាព និង គណនេយ្យភាព ចំពោះកម្មវិធីកែទម្រង់របស់ខ្លួន, និង ម្ខាងទៀត, ការផ្តល់ការគាំទ្រ និង កិច្ចសហការល្អ ប្រកបដោយធន្ទះមោះមុត ក្នុងការកែទម្រង់ ជាមួយនឹងកម្មវិធីកែទម្រង់ផ្សេងទៀត ។ និង

អភិក្រមទី ៤). **ភាពបុរេសកម្ម** ដែលសំដៅដល់ការប្រមើល និង ការត្រៀមលក្ខណៈដោះស្រាយបញ្ហាជាមួយគ្នា តាមរយៈយន្តការសម្របសម្រួលកិច្ចការកែទម្រង់គន្លឹះ នៃរាជ-រដ្ឋាភិបាល, ដែលយើងហៅកាត់ថា យ.ស.ក., ដោយមិនរង់ចាំ រហូតដល់បញ្ហាកើតឡើង ទើបចាប់ផ្តើមគិតគូរ និង ដាក់ចេញ នូវផែនការសកម្មភាព ដើម្បីដោះស្រាយ នោះឡើយ ។

## *ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី !*

ក្នុងនាមរាជរដ្ឋាភិបាល, ខ្ញុំសូមសម្តែងនូវកតញ្ញុតាធម៌ និង កតវេទិតាធម៌ យ៉ាងជ្រាលជ្រៅបំផុត គោរពជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលបានត្រួសត្រាយមាគ៌ា នៃសុខដុមនីយកម្ម កិច្ចការកែទម្រង់ ៣ បូក ១ ក្នុងនីតិកាលទី ៦ នៃរដ្ឋសភា កន្លងទៅ ។ ការណ៍នេះ បានធ្វើឲ្យរាជរដ្ឋាភិបាល សម្រាប់នីតិកាលទី ៧ នៃរដ្ឋសភា មានមូលដ្ឋានគ្រឹះដ៏រឹងមាំ ដើម្បីធ្វើបច្ចុប្បន្នកម្ម, រក្សាចលនការ និង ជំរុញបន្ថែមទៀត នូវជវភាពនៃការកែទម្រង់ សំដៅពង្រឹងអភិបាលកិច្ច ឲ្យបានកាន់តែប្រសើរឡើង ។ ទន្ទឹមនេះ, ខ្ញុំក៏សូមគោរពថ្លែងអំណរគុណ និង ការដឹងគុណ ដ៏ជ្រាលជ្រៅផងដែរ ចំពោះ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**, **នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**, ដែលបានផ្តល់ការគាំទ្រ និង បានផ្តល់អនុសាសន៍ណែនាំ ដ៏ខ្ពង់ខ្ពស់ លើការអនុវត្ត **ចក្ខុវិស័យ** និង **យុទ្ធសាស្ត្រ** នេះ ឲ្យបានជោគជ័យ តាមការរំពឹងទុក ។ យើងទាំងអស់គ្នាពិតជាមានភព្វសំណាងខ្ពស់ ដែលមាន **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី** ជាអ្នកបន្តវេន, ពោរពេញដោយបញ្ញាញាណភ្លឺថ្លា, ភាពជាអ្នកដឹកនាំដ៏ពិសិដ្ឋ, ភាពស្វាហាប់, ភាពវៃឆ្លាត និង ភាពប៉ិនប្រសប់ ប្រកបដោយចក្ខុវិស័យវែងឆ្ងាយ, ក្នុងការបន្តដឹកនាំនាវាកម្ពុជា ឆ្ពោះទៅកាន់ត្រើយដ៏សុខសាន្ត និង កាន់តែសម្បូររុងរឿង ។

ជាមួយគ្នានេះ, ខ្ញុំក៏សូមថ្លែងអំណរគុណ ឯកឧត្តមអភិសន្តិបណ្ឌិត **ស សុខា**, ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ, និង ជាប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ; ឯកឧត្តម **កើត រិទ្ធ**, ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រីក្រសួងយុត្តិធម៌, និង ជាសហប្រធានគណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌; ឯកឧត្តម **វង្សី វិស្សុត**, ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី, និង ជាប្រធានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់; និង ឯកឧត្តម **ហ៊ុន ម៉ានី**, ឧបនាយករដ្ឋមន្ត្រី, រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ, និង ជាប្រធានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ; ដែលតែងតែបានសហការ, ដឹកនាំ, និង ផ្តល់ការណែនាំ និង ការតម្រង់ទិសជាប្រចាំ ដល់យន្តការ យ.ស.ក. រហូតសម្រេចបាននូវបច្ចុប្បន្នកម្ម នៃ **ចក្ខុវិស័យ** និង **យុទ្ធសាស្ត្រ ស្តីពីសុខដុមនីយកម្ម កិច្ចការកែទម្រង់គន្លឹះ** នៃរាជរដ្ឋាភិបាល នេះឡើង ។

ខ្ញុំក៏សូមថ្លែងមូលវិចារណ៍ដ៏ថ្លៃថ្លា ជូនចំពោះក្រសួង-ស្ថាប័ន, អគ្គនាយកដ្ឋាន និង អង្គភាពនានា, ជាពិសេស ថ្នាក់ដឹកនាំ និង មន្ត្រី នៃអគ្គលេខាធិការដ្ឋាន និង លេខាធិការ-ដ្ឋានកែទម្រង់នីមួយៗ ដែលបានសហការល្អ និង បានគាំទ្រគ្នាទៅវិញទៅមក ប្រកបដោយសាមគ្គីភាព, ស្មារតីទទួលខុសត្រូវ, ឆន្ទៈកែទម្រង់, និង ស្តង់ដាវិជ្ជាជីវៈ ក្នុងនាមជាសេនា-ធិការដ៏ចំណាន របស់គណៈកម្មាធិការដឹកនាំការកែទម្រង់រៀងៗខ្លួន ។

មុននឹងបញ្ចប់, ខ្ញុំដាក់ក្តីរំពឹងថា **ចក្ខុវិស័យ និង យុទ្ធសាស្ត្រ ស្តីពីសុខដុមនីយកម្ម កិច្ចការកែទម្រង់គន្លឹះ នៃរាជរដ្ឋាភិបាល** នឹងក្លាយជាមគ្គុទេសក៍ដ៏រស់រវើក សម្រាប់ការអនុវត្តយន្តការ **យ.ស.ក.** ។ ខ្ញុំសូមលើកទឹកចិត្ត ដល់ក្រសួង-ស្ថាប័ន និង អង្គភាពទាំងឡាយ ដែលជាតួអង្គពាក់ព័ន្ធ បន្តចូលរួមអនុវត្ត និង ដកស្រង់បទពិសោធន៍ និង មេរៀនល្អៗ ក្នុងកិច្ចដំណើរការនៃការអនុវត្ត **ចក្ខុវិស័យ និង យុទ្ធសាស្ត្រ** នេះ ដើម្បីមានមូលដ្ឋានកាន់តែរឹងមាំឡើងថែមទៀត សំដៅពង្រឹងគុណភាពអភិបាលកិច្ច, រួមចំណែកបម្រើឧត្តមប្រយោជន៍ជាតិ និង ប្រជាជន ឲ្យបានកាន់តែប្រសើរឡើង ។

ជាទីបញ្ចប់, ខ្ញុំសូមជូនពរ ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី, ភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិ, សមាជិក-សមាជិកានៃអង្គពិធី បានសមប្រកបដោយសុខភាពល្អបរិបូរណ៍, សម្រេចបានជោគជ័យក្នុងគ្រប់ភារកិច្ច, ព្រមទាំងទទួលបាននូវវិបុលភាព និង សុភមង្គល ក្នុងក្រុមគ្រួសាររៀងៗខ្លួន នៅក្រោមម្លប់ដ៏ត្រជាក់នៃសុខសន្តិភាព ។

តាងនាម **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**, **នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**, ខ្ញុំសូមប្រកាសដាក់ឲ្យប្រើជាផ្លូវការ នូវ ចក្ខុវិស័យ និង យុទ្ធ-សាស្ត្រ ស្តីពីសុខដុមនីយកម្ម កិច្ចការកែទម្រង់គន្លឹះ នៃរាជរដ្ឋាភិបាល ចាប់ពីពេលនេះតទៅ ៕

***សូមអរគុណ!***